00754239



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 21-Nov-2011, 17:04
CMS/CFO: Uch Arun

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour suprême

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧-អ.វ.ត.ក/អ.ជ.ស.ដ/អ.ជ.ត.ក (៩)
Case File/Dossier N°. 002/19-09-2007-ECCC-TC/SC(9)

**នៅចំពោះមុខ៖**

ចៅក្រម គង់ ស្រ៊ីម ប្រធាន
ចៅក្រម Motoo NOGUCHI
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម Agnieszka KLONOWIECKA-MILART
ចៅក្រម ម៉ុង មុន្នីចារិយា
ចៅក្រម Chandra Nihal JAYASINGHE
ចៅក្រម យ៉ា ណារិន

**កាលបរិច្ឆេទ៖** ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១១
**ភាសា៖** អង់គ្លេស/ខ្មែរ
**ចំណាត់ថ្នាក់ឯកសារ៖** សាធារណៈ

---

# សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំដាក់សារណាបន្ថែម និងសេចក្តីណែនាំពាក់ព័ន្ធនឹងការដាក់បណ្តឹងសាទុក្ខ

---

**សហព្រះរាជអាជ្ញា:**

ជា លាង
Andrew CAYLEY

**ជនជាប់ចោទ**

នួន ជា
អៀង សារី
អៀង ធីរិទ្ធ
ខៀវ សំផន

**មេធាវីជនជាប់ចោទ**

Diana ELLIS, QC
ផាត់ ពៅស៊ាង

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ
Elisabeth SIMONNEAU FORT

សុន អរុណ

Michiel PESTMAN
Victor KOPPE

អាង ឧត្តម

Michael G. KARNAVAS

សរ ស្ទូវាន

Jacques VERGÈS

00754241



**អង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា :**

**ដោយបានទទួល**បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា[១] ("បណ្តឹងសាទុក្ខ") ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១ ដែលបង្គាប់ឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ពីមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក[២] ដែលនៅក្នុងបណ្តឹងសាទុក្ខនោះ សហព្រះរាជអាជ្ញាបានស្នើឲ្យអង្គជំនុំជម្រះតុលាការកំពូលកែតម្រូវសេចក្តីសម្រេចដោះលែង "ដោយបង្គាប់ឲ្យជនជាប់ចោទបន្តស្ថិតនៅក្នុងការឃុំខ្លួន និងទទួលការព្យាបាលផ្នែកវេជ្ជសាស្ត្រ និងការកែលម្អសុខភាពផ្សេងទៀត ដូចដែលអ្នកជំនាញផ្នែកវេជ្ជសាស្ត្របានផ្តល់អនុសាសន៍ ដោយត្រូវធ្វើការត្រួតពិនិត្យសុខភាពឡើងវិញក្នុងរយៈពេល ០៦ខែ"[៣]។

**ដោយកត់សម្គាល់** សំណើរបស់សហព្រះរាជអាជ្ញានៅក្នុងបណ្តឹងសាទុក្ខរបស់ខ្លួនសុំអនុញ្ញាតដាក់សារណាបណ្តឹងសាទុក្ខបន្ថែមជាលាយលក្ខណ៍អក្សរ "ក្នុងរយៈពេលប្រាំពីរ (៧) ថ្ងៃ" បន្ទាប់ពីការដាក់បណ្តឹងសាទុក្ខ ដោយបង្ហាញហេតុផលថា "ដោយសារពេលវេលាខ្លីពេក [២៤ម៉ោង] ក្នុងការប្តឹងសាទុក្ខដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង បណ្តឹងសាទុក្ខនេះមិនអាចបង្ហាញបានគ្រប់ឯកសារគាំទ្រ និងទឡ្ហីករណ៍ឡើយ" ("សំណើ")[៤]។

**ដោយពិចារណា** លើសារៈសំខាន់បញ្ហាថាតើ ជនជាប់ចោទគួរត្រូវបានដោះលែងពីមន្ទីរឃុំឃាំង ដែរ ឬយ៉ាងណា និងស្ថិតក្រោមលក្ខខណ្ឌបែបណាខ្លះ និងដោយពិចារណាទៅលើពេលវេលាដ៏ខ្លី ដែលអង្គជំនុំជម្រះតុលាការកំពូលត្រូវចេញសេចក្តីសម្រេចរបស់ខ្លួនលើបណ្តឹងសាទុក្ខ[៥]។

---

[១] បណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបង្គាប់ឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ឯកសារ E138/1/1 ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១១។

[២] សេចក្តីសម្រេចលើសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ ឯកសារ E138។

[៣] បណ្តឹងសាទុក្ខ កថាខណ្ឌ ១៩។

[៤] បណ្តឹងសាទុក្ខ កថាខណ្ឌ ២០។

[៥] វិធានផ្ទៃក្នុង ៨២(៦) ("បណ្តឹងសាទុក្ខនេះត្រូវសម្រេចដោយអង្គជំនុំជម្រះតុលាការកំពូលក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃបន្ទាប់ពីក្រឡាបញ្ជីរបស់អង្គជំនុំជម្រះតុលាការកំពូលទទួលបានសំណុំរឿង")។

**អនុលោមតាម**វិធាន ៣៩(២)នៃវិធានផ្ទៃក្នុង និងមាត្រា ៨(១) នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក (វិសោធនកម្មលើកទី៧)។

**សម្រេច**

**ទទួលយក** តាមសំណើរបស់សហព្រះរាជអាជ្ញាមួយផ្នែក ដោយអនុញ្ញាតឲ្យសហព្រះរាជអាជ្ញាត្រូវបានដាក់សារណាបណ្តឹងសាទុក្ខបន្ថែមជាលាយលក្ខណ៍អក្សរ មិនឲ្យហួសពីថ្ងៃអង្គារ ទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១១ និង**បង្គាប់**ថា សារណាបន្ថែមនោះមិនអាចមានចំនួនលើសពី ១០ទំព័រ ជាភាសាអង់គ្លេស ឬភាសាបារាំង និង ២០ទំព័រ ជាភាសាខ្មែរបានឡើយ។

**បង្គាប់ថា** ជនជាប់ចោទត្រូវតែដាក់សារណាតបទៅនឹងបណ្តឹងសាទុក្ខ សារណាបណ្តឹងសាទុក្ខបន្ថែមជាលាយលក្ខណ៍អក្សរ និង/ឬចំពោះគ្រប់សារណាបណ្តឹងសាទុក្ខរបស់ភាគីផ្សេងៗទៀត ត្រឹមថ្ងៃច័ន្ទ ទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១១ និង

**បង្គាប់ថា** សារណាតបណាមួយក៏ដោយរបស់ជនជាប់ចោទមិនអាចមានចំនួនលើសពី ២០ទំព័រ ជាភាសាអង់គ្លេស ឬភាសាបារាំង និង ៤០ ទំព័រ ជាភាសាខ្មែរបានឡើយ។

**បង្គាប់ថា** ភាគីផ្សេងទៀតដែលមិនមែនជាជនជាប់ចោទ មិនអាចដាក់សារណាតបទៅនឹងបណ្តឹងសាទុក្ខ និងសារណាបណ្តឹងសាទុក្ខបន្ថែមជាលាយលក្ខណ៍អក្សររបស់សហព្រះរាជអាជ្ញាបានឡើយ ។ និង

**បង្គាប់** ថា មិនអនុញ្ញាតឲ្យមានការដាក់ការឆ្លើយតបទៅនឹងសារណាតបរបស់ជនជាប់ចោទឡើយ។

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១១

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រីម**